**តារាង ២.១**

**វឌ្ឍនភាពឆ្ពោះទៅរកគោលដៅ ៩០-៩០-៩០ តាមប្រទេសនីមួយៗ ក្នុងចំណោមប្រទេសដែលមានសេវាព្យាបាលស្មើ ឬធំជាងអត្រាមធ្យមប្រចាំឆ្នាំ ២០១៩ ***

| | People living with HIV who know their status | People living with HIV who know their status and are on treatment | People on treatment who are virally suppressed | | Viral load suppression among people living with HIV |
|---|---|---|---|---|---|
| **ACHIEVED 2030 TARGET (95%)** | ***Eswatini***<br>**Namibia** | Burundi<br>Cambodia<br>Denmark<br>***Eswatini***<br>Haiti<br>Rwanda<br>Senegal<br>**Switzerland**<br>**Zambia** | **Australia**<br>Botswana<br>Cambodia<br>***Eswatini***<br>Germany<br>Ireland<br>Japan<br>Myanmar<br>**Netherlands**<br>**Switzerland**<br>Thailand<br>Viet Nam | **ACHIEVED 2030 TARGET (86%)** | ***Eswatini***<br>**Switzerland** |
| **ACHIEVED 2020 TARGET (90%)** | **Australia**<br>Botswana<br>Chile<br>Guyana<br>Ireland<br>Kenya<br>Malawi<br>**Netherlands**<br>South Africa<br>**Switzerland**<br>**Zambia**<br>Zimbabwe | **Australia**<br>Burkina Faso<br>Ethiopia<br>Germany<br>Morocco<br>**Namibia**<br>**Netherlands**<br>Singapore<br>Spain<br>Uganda<br>United Republic of Tanzania<br>Zimbabwe | Brazil<br>Chile<br>Kenya<br>Malawi<br>Morocco<br>**Namibia**<br>Rwanda<br>Singapore<br>South Africa<br>Spain<br>Trinidad and Tobago<br>Uganda<br>United Republic of Tanzania<br>**Zambia** | **ACHIEVED 2020 TARGET (73%)** | **Australia**<br>Botswana<br>Cambodia<br>Ireland<br>**Namibia**<br>**Netherlands**<br>Rwanda<br>Spain<br>Thailand<br>Uganda<br>**Zambia**<br>Zimbabwe |
| **NEARLY ACHIEVED 2020 TARGET (85–89%)** | Brazil<br>Burundi<br>Cuba<br>Italy<br>Romania<br>Rwanda<br>Spain<br>Uganda<br>United States of America | Algeria<br>Botswana<br>Cuba<br>Ireland<br>Italy<br>Luxembourg<br>Malawi<br>Peru<br>Portugal<br>Slovakia | Ethiopia<br>Guyana<br>Italy<br>Luxembourg<br>Portugal<br>Zimbabwe | **NEARLY ACHIEVED 2020 TARGET (68–72%)** | Italy<br>Kenya<br>Malawi<br>Myanmar<br>United Republic of Tanzania |

* បណ្តាប្រទេសមានសិទ្ធិទទួលបានការដាក់បញ្ចូលក្នុងតារាង ប្រសិនបើការគ្របដណ្តប់ការព្យាបាលមេរោគអេដស៍ស្មើ ឬធំជាងការគ្របដណ្តប់ការព្យាបាលមេរោគអេដស៍ទូទាំងពិភពលោក ក្នុងឆ្នាំដែលពួកគេបានរាយការណ៍ទិន្នន័យចុងក្រោយ (ការគ្របដណ្តប់ការព្យាបាលជាសកល៖ ៤៩% ក្នុងឆ្នាំ២០១៥ ៥៤% ក្នុងឆ្នាំ២០១៦ ៥៩% នៅ ឆ្នាំ២០១៧) ៦២% ក្នុងឆ្នាំ២០១៨ និង ៦៧% នៅឆ្នាំ២០១៩) ។ ក្រៅពីនេះ បណ្តាប្រទេសនានាក៏ត្រូវផ្សព្វផ្សាយការប៉ាន់ស្មាននៃអ្នកផ្ទុកមេរោគអេដស៍ ដែលនឹងត្រូវ ដាក់បញ្ចូលទៅក្នុងប្រអប់ជួរឈរដែលពិពណ៌នាអំពីវឌ្ឍនភាពឆ្ពោះទៅរកអ្នកផ្ទុកមេរោគអេដស៍ដែលដឹងពីស្ថានភាពរបស់ពួកគេ និងការទប់ស្កាត់ការផ្ទុកវីរុសក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ ការប៉ាន់ស្មានគឺសម្រាប់ឆ្នាំ២០១៩ លើកលែងតែដូចខាងក្រោម៖ សម្រាប់ឆ្នាំ២០១៥៖ ជប៉ុន សម្រាប់ឆ្នាំ២០១៦មាន៖ ដាណឺម៉ាក អ៊ីតាលី ព័រទុយហ្គាល់ និងអេស្ប៉ាញ; សម្រាប់ឆ្នាំ២០១៧មាន៖ អាឡឺម៉ង់ ប៉េរូ និងស្លូវ៉ាគី និងសម្រាប់ឆ្នាំ ២០១៨មាន៖ អូស្ត្រាលី អៀរឡង់ ហូឡង់ សិង្ហបុរី និងសហរដ្ឋអាមេរិក។ ចំណែកប្រទេស អេសស្វាទីនី ដែលបញ្ជាក់ដោយអក្សរទ្រេតពណ៌ដិត បានឈានដល់គោលដៅទាំងបីនៃគោលដៅ ៩៥-៩៥-៩៥ នាឆ្នាំ២០៣០ រួចហើយ។ រីឯប្រទេសអូស្ត្រាលី ណាមីប៊ី ហូល្លង់ ស្វីស និងហ្សំប៊ី ដែលបានសរសេរជាអក្សរដិតបានរាយការណ៍ថាឈានដល់គោលដៅនីមួយៗនៃឆ្នាំ ៩០-៩០-៩០ នៅឆ្នាំ ២០២០ ។

មិនមានការប៉ាន់ស្មានទេនៅពេលបោះពុម្ពផ្សាយសម្រាប់៖ ប្រទេសអាន់ដូរ៉ា អាហ្សង់ទីន អូទ្រីស សហព័ន្ធប៉ាហាមាស បារ៉ែន បង់ក្លាដែស បែលហ្ស៊ិក ប៊ូតាន់ប្រ៊ុយណេដារូសាឡឹម កាណាដា ចិន កោះឃ្វីស ស៊ីប ឆែក ហ្វាំងឡង់ បារាំង ក្រិក អៀឡង់ ឥណ្ឌា, ឥណ្ឌូនេស៊ី អ៊ីរ៉ាក់ អ៊ីស្រាអែល ហ្សកដានី គីរីបាទី គុយវ៉ែត ឡាតវី ឡិចធិនស្តែន ម៉ាល់ឌីវ ម៉ាល់តា កោះម៉ាសល មីក្រូណេស៊ី (រដ្ឋសហព័ន្ធ) កោះណូរុ នូវែលសេឡង់ Niue ន័រវែស ប៉ាឡូ ប៉ាណាម៉ា ប៉ារ៉ាហ្គាយ Poland កាតា កូរ៉េខាងត្បូង សៅតូមេនិងព្រីនស៊ីប អារ៉ាប៊ីសាអ៊ូឌីត សែប៊ី ស្លូវេនី សូម៉ាលី ស៊ុយអែត សាធារណរដ្ឋអារ៉ាប់ ស៊ីរី តុងហ្គា តួកគី ទុយស្លួយ អារ៉ាប់រួម ចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើង អ៊ូសបេគីស្ថាន និងវ៉ានូអាទូ។
ប្រភព៖ ការប៉ាន់ស្មានអំពីរោគរាតត្បាតឆ្នាំ២០២០ របស់អង្គការ UNAIDS (សូមមើល https://aidsinfo.unaids.org/)។

## ការរួមបញ្ចូលគ្នានៃការបង្ការ សម្រាប់ក្រុមប្រជាជនគន្លឹះ

ចំនួនប្រជាជនគន្លឹះទទួលបានការបង្ការការឆ្លងមេរោគអេដស៍ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងក្នុងចំណោមប្រទេសនានា ហើយវានៅមិនទាន់គ្រប់គ្រាន់នៅឡើយទេនៅទូទាំងពិភពលោក។ នៅក្នុងប្រទេសចំនួន ៦ ក្នុងចំណោមប្រទេសចំនួន ១៣ ដែលបានធ្វើការស្ទង់មតិតាំងពីឆ្នាំ ២០១៦ និងបានរាយការណ៍អំពីទិន្នន័យទាំងនោះទៅអង្គការ UNAIDS ដែលមានចំនួនតិចជាងពាក់កណ្តាលនៃស្ត្រីបំប្លែងភេទបាននិយាយថា ពួកគេអាចទទួលបានសេវាបង្ការមេរោគអេដស៍យ៉ាងហោចណាស់ ចំនួន ២ ក្នុងរយៈពេលបីខែចុងក្រោយនេះ (រូបភាព ២.១៣)។ ក្រុមស្ត្រីបម្រើការនៅសេវាកម្សាន្ត មាននៅក្នុងប្រទេសចំនួន ១៦ ក្នុងចំណោមប្រទេសចំនួន ៣០ ដែល បានរាយការណ៍ (រូបភាពទី ២.១៤)។ ចំពោះក្រុមបុរសរួមភេទបុរស និងបុរសដទៃទៀតដែលបានរួមភេទជាមួយបុរស មាននៅប្រទេសចំនួន ២៦ ក្នុងចំណោមប្រទេសចំនួន ៣៨ បានរាយការណ៍ (រូបភាព ២.១៥) និងចំពោះក្រុមបុរសចាក់ថ្នាំញៀន មានប្រទេសចំនួន ១០ នៃ ១៤ ប្រទេសដែលបានរាយការណ៍ (រូបភាព ២.១៦) ។

### រូបភាព ២.១៣

**ស្ត្រីបំប្លែងភេទដែលបានរាយការណ៍ថាទទួលបានសេវាកម្មបង្ការយ៉ាងហោចណាស់ពីរ ក្នុងរយៈពេលបីខែកន្លងមកនេះ នៅប្រទេសដែលមានទិន្នន័យដែលអាចរកបាន នៅចន្លោះឆ្នាំ ២០១៦-២០១៩**




ប្រភព៖ ការត្រួតពិនិត្យតាមដានជំងឺអេដស៍សកលឆ្នាំ២០២០ របស់អង្គការ UNAIDS ( សូមមើល https://aidsinfo.unaids.org/ )។
សម្គាល់៖ ការប្រើប្រាស់សញ្ញាផ្កាយ ( * ) បង្ហាញថាទិន្នន័យសម្រាប់ប្រទេសដែលបានសម្គាល់បានមកពីទិន្នន័យកម្មវិធី (ដែលបង្ហាញពីតម្លៃខ្ពស់) និងមិនមែនមកពីការស្ទង់មតិ។
សេវាបង្ការដែលអាចទទួលបានគឺ៖ ស្រោមអនាម័យនិងទឹករំអិល ការផ្តល់ប្រឹក្សាលើការប្រើប្រាស់ស្រោមអនាម័យនិងការរួមភេទប្រកបដោយសុវត្ថិភាព និងការធ្វើតេស្តរកជំងឺកាមរោគ។

## រូបភាព ២.១៤

### ក្រុមស្ត្រីបម្រើការនៅកន្លែងកម្សាន្ត ជាក្រុមស្ត្រីដែលបានរាយការណ៍ថាបានទទួលសេវាបង្ការយ៉ាងហោចណាស់ចំនួនពីរ ក្នុងរយៈពេលបីខែកន្លងមកនេះ នៅប្រទេសដែលមានទិន្នន័យដែលអាចរកបាន នៅចន្លោះឆ្នាំ២០១៦-២០១៩




ប្រភព៖ ការត្រួតពិនិត្យតាមដានជំងឺអេដស៍សកលឆ្នាំ២០២០ របស់អង្គការ UNAIDS ( សូមមើល https://aidsinfo.unaids.org/ )។

សម្គាល់៖ ការប្រើប្រាស់សញ្ញាផ្កាយ ( * ) បង្ហាញថាទិន្នន័យសម្រាប់ប្រទេសដែលបានសម្គាល់បានមកពីទិន្នន័យកម្មវិធី (ដែលបង្ហាញពីតម្លៃខ្ពស់) និងមិនមែនមកពីការស្ទង់មតិ។

សេវាបង្ការ ដែលអាចទទួលបានគឺ៖ ស្រោមអនាម័យនិងទឹករំអិល ការផ្តល់ប្រឹក្សាពីការប្រើប្រាស់ស្រោមអនាម័យនិងការរួមភេទប្រកបដោយសុវត្ថិភាព និងការធ្វើតេស្តរកជំងឺកាមរោគ។

**រូបភាព ២.១៥**

**ក្រុមបុរសរួមភេទជាមួយបុរស និងបុរសដទៃទៀតដែលបានរួមភេទជាមួយបុរស ដែលបានរាយការណ៍ថាទទួលបានសេវាបង្ការ យ៉ាងហោចណាស់ពីរ ក្នុងរយៈពេលបីខែកន្លងមក នៅប្រទេសដែលមានទិន្នន័យដែលអាចរកបាន នៅចន្លោះឆ្នាំ២០១៦-២០១៩**




ប្រភព៖ ការត្រួតពិនិត្យតាមដានជំងឺអេដស៍សកលឆ្នាំ២០២០ របស់អង្គការ UNAIDS ( សូមមើល https://aidsinfo.unaids.org/ )។
សម្គាល់៖ ការប្រើប្រាស់សញ្ញាផ្កាយ ( * ) បង្ហាញថាទិន្នន័យសម្រាប់ប្រទេសដែលបានសម្គាល់បានមកពីទិន្នន័យកម្មវិធី (ដែលបង្ហាញពីតម្លៃខ្ពស់) និងមិនមែនមកពីការស្ទង់មតិ។
សេវាបង្ការ ដែលអាចទទួលបានគឺ៖ ស្រោមអនាម័យនិងទឹករំអិល ការផ្តល់ប្រឹក្សាពីការប្រើប្រាស់ស្រោមអនាម័យនិងការរួមភេទប្រកបដោយសុវត្ថិភាព និងការធ្វើតេស្តរកជំងឺកាមរោគ។

## រូបភាព ២.១៦

### ក្រុមបុរសចាក់គ្រឿងញៀន ដែលរាយការណ៍ថាបានទទួលសេវាបង្ការយ៉ាងហោចណាស់ពីរ ក្នុងរយៈពេលបីខែកន្លងមក នៅប្រទេសដែលមានទិន្នន័យដែលអាចរកបាន នៅចន្លោះឆ្នាំ ២០១៦-២០១៩




ប្រភព៖ ការត្រួតពិនិត្យតាមដានជំងឺអេដស៍សកលឆ្នាំ២០២០ របស់អង្គការ UNAIDS ( សូមមើល https://aidsinfo.unaids.org/ )។

សម្គាល់៖ ការប្រើប្រាស់សញ្ញាផ្កាយ ( * ) បង្ហាញថាទិន្នន័យសម្រាប់ប្រទេសដែលបានសម្គាល់បានមកពីទិន្នន័យកម្មវិធី (ដែលបង្ហាញពីតម្លៃខ្ពស់) និងមិនមែនមកពីការស្ទង់មតិ។

សេវាកម្មបង្ការដែលអាចទទួលបានគឺ៖ស្រោមអនាម័យនិងប្រេងរំអិល ការផ្តល់ប្រឹក្សាពីការប្រើប្រាស់ស្រោមអនាម័យនិងការរួមភេទប្រកបដោយសុវត្ថិភាព និងឧបករណ៍ចាក់ដែលគ្មានមេរោគ។



*Credit: UNAIDS*